ទោះនាងមិនដឹងគោលដៅដែលត្រូវទៅ និងមិនស្គាល់ផ្លូវទៅរកពេទ្យសាននោះនៅឯណាក្តី នាងត្រៀមជាស្រេចហើយក្នុងការរត់រកជំនួយ។

«ទៅក្រៅបត់ស្តាំ! ផ្ទះលក់ថ្នាំនៅក្បែរដើមម៉ៃសាក់ កែងផ្លូវគ្រួសក្រហម!»

នាងពិតជាបានឃើញឱសថស្ថានតូចមួយពិតមែន មុនពេលបរឡានចូលមកដល់ទីនេះ។

«ចាំបង!»

ឆ្លើយតបដោយខ្លីហើយ ស្រីអ្នកកាសែតរត់រឹងចាកចេញ។

**ជំពូកទី៣**

**វុឌ្ឍិវិថី**

ផ្ទះលក់ថ្នាំមានការរៀបចំរបៀបជាឱសថស្ថានទំនើបមិនចាញ់ទីប្រជុំជននានាទោះបីស្ថិតនៅចំកែងផ្លូវលំពីរខ្សែតូចៗក្តី។

ដើមម៉ៃសាក់ប្រញឹកនៅក្បែរហាងបញ្ជាក់ជាស្រេចថានាងបានមករកឃើញត្រូវកន្លែងហើយ។

នៅពីក្រោយទូកញ្ចក់វែងដែលមានតម្រៀបដបអាល់កុលនិងពពួកថ្នាំ នាងមិនឃើញមានមនុស្សប្រចាំនៅទេ។ ធីតាសម្លឹងឆ្ពោះទៅខាងក្នុងល្វែងផ្ទះដែលសង់ថ្មក្រោម និងឈើខាងលើចាប់ពីធ្នឹមនិងពិតាន។ ក្រៅពីគ្រែពេទ្យមួយ និងដងព្យួរសេរ៉ូម បិទបាំងដោយឡប់ឡែបំពាក់វាំងននក្រណាត់ពណ៌ផ្ទៃមេឃខ្ចី នាងមិនឃើញអ្នកណាទាំងអស់។

«មានអ្នកណានៅទេ?!»

នាងស្រែកសួរទាំងសំឡេងញ័រទោះមិនបានរត់មកឆ្ងាយក្តី។ ទ្វារខ្លីមួយត្រូវបានគេភ្ជាប់ជាមួយទូកញ្ចក់នោះ សម្រាប់រារាំងមិនអនុញ្ញាតឱ្យភ្ញៀវឈានចូលទៅក្នុងផ្ទះបាន ប៉ុន្តែទំនងជារការពារដោយរនុកមួយមិនជាមាំប៉ុន្មានឡើយ។

ទីនេះនិងផ្ទះក្រអូបមិនឆ្ងាយជាង១០០ម៉ែត្រសោះ ប៉ុន្តែសំឡេងនាងដែលញ័រទំនងមកពីព្រឹត្តិការណ៍នៃបុរសចំណាស់។

មិនឃើញមានប្រតិកម្មណាមួយតបនឹងសំណួរនាងកាន់តែអន្ទះសា។

«ពេទ្យសានៗ?»

នាងស្រែកហៅផ្ទួនៗដោយឈានទៅមុខបន្ថែមបម្រុងនឹងចូលទៅក្នុងផ្ទះតាមរយៈទ្វារដែលភ្ជាប់នឹងទូកញ្ចក់។

«កុំឱ្យសោះ!»

សំឡេងសោះកក្រោះមួយលាន់មកក្បែរនាង ក្បែរមែនទែន ប៉ុន្តែមិនមែនមានទិសដៅមកពីខាងក្នុងផ្ទះទេ គឺពីក្រោយនាងទៅវិញ។

អ្នកកាសែតបែរខ្វាក។ ក្បែរនាងមិនដល់ពីរជំហាន យុវជនមួយរូប មានសម្បុរសជ្រះ វ័យប្រមាណជា ២៥ ឆ្នាំ កំពុងឈរកាន់ធុងទឹកស្រោចដំណាំមួយ ផ្ទុយពីសម្លៀកបំពាក់ទីនុយដូចជាមន្ត្រីរាជការរបស់នាយ។

ទឹកមុខបុរសនេះ មិនត្រឹមតែហាក់បីមិនស្វាគមន៍នាង ថែមទាំងចោលភ្នែកឆ្ងល់ ក៏ដូចជាមិនពេញចិត្ត។

ទំនងគាត់គិតថា នាងចង់លុកចូលផ្ទះនេះដោយគ្មានការអនុញ្ញាតហើយ។ នាងសម្រេចចិត្តទម្លាក់ចោលការអាក់អន់ចំពោះកិរិយារបស់គេ ហើយនិយាយដោយឱនលំទោន៖

«សុំទោស! ខ្ញុំស្លន់ពេក!»

បុរសនោះសម្លឹងនាងពីលើដល់ក្រោមមុនពេលដាក់ធុងទឹកចុះ។ គេដើរចោលនាងក្រោយពីសម្លឹងមួយត្រួសហើយហួសទៅចូលក្នុងផ្ទះ តាមរយៈទ្វារទាបខ្លីមួយកំណាត់នោះ។ ចូលដល់ផ្នែកខាងក្នុងកាលណាគេប្រញាប់បិទរនុកវិញហាក់មិនចង់ឱ្យនាងឈានមកតាម។

កិរិយាប្រយ័ត្នប្រយែងហួសនេះធ្វើឱ្យនាងកាន់តែមានទំនោរស្រងាកចិត្តថែមឡើង។

«មនុស្សនៅភូមិនេះយ៉ាប់ៗណាស់! ជាយុវវ័យដែលតែអាកប្បកិរិយាឈ្លើយ»

នាងគិតតែមិនហ៊ានមានប្រតិកម្មអ្វី។ សម្ដីនាងបែរជាទន់ភ្លន់ខុសពីចិត្ត៖

«ពេទ្យសានមែនទេ? ជួយមើលផងពូ ពូសំភិនមានគ្រោះថ្នាក់!»

ទឹកមុខងឿងឆ្ងល់និងប្រុងប្រយ័ត្ននៃបុរសនេះស្រាប់តែប្ដូរផ្លាស់ទៅជាស្លេកភ័យ។ ប្រតិកម្មនាយរហ័សពេក ហាក់ដូចបន្ថែមទំងន់បញ្ហាក្នុងបេះដូងអ្នកកាសែត។

មួយថ្ងៃនេះ បេះដូងយើងរងទុក្ខនឹងមនុស្សចម្លែកៗ រឿងចម្លែកៗច្រើនពេកហើយ!

នាងគិតម្នាក់ឯងដោយស្វ័យប្រវត្តិ តែមិនមាត់ទេថែមទាំងរក្សាទឹកមុខបានដដែល ឯមាត់ក៏បន្ទរបន្ថែម៖

«អ្នកបងចរិយាឱ្យខ្ញុំមកហៅពេទ្យសានទៅភ្លាម! ពូសំភិនបែកពពុះមាត់ហើយ!»

ពេទ្យសានទំនងជាគេនេះហើយបើតាមអារម្មណ៍សម្ងាត់មួយបង្ហើបបង្ហាញនាង។

គេរភ្នែកគិតយ៉ាងរាងវៃ។

ពីក្រោយខ្នងគេដែលកំពុងឱ្យរើយកសម្ភារៈ នាងឃើញស្លាកវេជ្ជបណ្ឌិត របស់គេព្យួរតាំងច្បាស់ទេង។ នាងបន្ទោសខ្លួនឯងដែលតក្កមាពេកភ្លេចឃើញសញ្ញាបត្ររបស់គេ។

បុរសក្មេងឆ្មើងឆ្មៃមិនញញឹមនេះតាមពិតជាពេទ្យសានហ្នឹងមែនហើយ។ មួយក្រឡេកបន្ថែមប៉ុណ្ណោះនាងឃើញឈ្មោះពេញរបស់គេ «វេជ្ជ.តាំង គីមសានឯកទេសជំងឺទូទៅ»។

«តោះ!»

គេនិយាយខ្លីរួចចាកចេញមកក្រៅហាង ដៃម្ខាងយួរកាតាបពេទ្យដៃម្ខាងទាញទ្វារទាំងសងបិទនិងចាក់សោយ៉ាងប្រុងប្រយ័ត្នហើយរហ័សរហួន។

ទីនេះមានតែគេម្នាក់? គ្មានជំនួយការទេ?

នាងគិតម្នាក់ឯងតែមិនបានសួរឡើយ។

ពេលគេបោះជំហានឆ្ពោះទៅកាន់ផ្ទះក្រអូប នាងឈានជើងតាមគេសឹងមិនទាន់ព្រោះជង្គង់វែងៗនិងដំណើរដ៏ច្រវាត់រហ័សរបស់គេ។ ស្រីស្អាតរត់ត្រុកៗតាមពីក្រោយទាំងងឿងឆ្ងល់ព្រោះគេចាប់ផ្តើមថ្មើរជើងខុសពីគោលដៅ។

«ទៅផ្ទះក្រអូបណ៎ា! ផ្ទះឧកញ៉ាវុទ្ធី!»

នាងរំឭកគេ។ គេនោះនៅតែបន្តដំណើរតាមផ្លូវរបៀងតូចៗ សំបូរទៅដោយកូនរុក្ខជាតិតូចៗនិងចន្លោះល្មមតែមនុស្សម្នាក់ដើរបាន។

«ត្រូវជាអីនឹងគាត់?»

គេសួរខ្លីៗម៉ាត់ៗ ចំណែកជើងនៅតែញាប់ឡើងៗរហូតនាងត្រូវរត់ទើបតាមទាន់។

មាត់នាងឆ្លើយតបដោយមិនបង្អង់៖

«ពូរុទ្ធីហ្មេន? ខ្ញុំក្អួយគាត់ឈ្មោះធីតា!»

នាយពេទ្យស្រាប់តែឈប់ង៉ក់ ធ្វើឱ្យស្រីអ្នកកាសែតដែលមិនអាចទាយដឹងមុនអំពីកាយវិការនេះ ជ្រុលដំណើរ ដែលខំត្រដរមកតាមឱ្យទាន់នោះហើយបុករាងកាយខ្លួនភឹងទៅនឹងស្មានាយពីក្រោយ។

សន្ទុះកម្លាំងរត់ខ្លាំងប៉ុនណា ការភ្លាត់ខ្នាតមកវិញក៏ខ្លាំងកម្រិតនោះធ្វើឱ្យរាងកាយស្រីត្រូវផ្ងារក្រោយ ត្រៀមតែផ្ទប់នឹងគល់ឈើក្បែរកូនរុក្ខវិថី បើកុំតែបានកំភួនដៃនាយយារមកយោងទាញឡើងមកវិញមួយទំហឹង កុំអីមិនដឹងអ្វីទៅដែលនឹងស្វាគមន៍ធីតាឡើយ។ អាចជាមែកឈើមានបន្លាស្រួច ឬអាចថាជាដីក្រហមគ្រើមរឹងទាំងនោះផងមិនដឹង។

ពេលនេះនាងត្រូវយោងបកក្រោយ បោលផ្ទប់មុខទៅនឹងអ្វីមួយទន់ល្មើយ។

ក្នុងភាពភាន់ភាំងនាងអាចស្តាប់ឮចង្វាក់ដង្ហើម។ ពិតហើយនេះ ជាដើមទ្រូងបុរសម្នាក់ដែលទើបនឹងសង្គ្រោះនាងបានមុននេះ ត្រឹមមួយប៉ព្រិចភ្នែក។

នាងប្រមូលអារម្មណ៍មកវិញ ហើយស្ទុះក្រោកចេញពីលង្វែកទ្រូងពេទ្យឆ្មើងឆ្មៃ។

ជើងស្តាំឈឺណាស់ ឈឺរហូតដល់នាងត្រូវភ្លាត់មាត់ អ៊ូយ! ខ្លី។

«ដើរទៀតកើតដែរ?»

គេងាកមកសម្លឹងនាងដោយកែវភ្នែកស្រទន់។

ភ្នែកពេទ្យនេះ ក្រៅពីបញ្ឈប់នៅត្រង់ផ្ទៃមុខស្រស់ស្រទន់ គេបង្ហួសមកសម្លឹងសម្រស់ក្រោមកអាវរបស់នាង។

ធីតាច្បាមអាវបិទបាំង ហើយប្រឹងទប់ជំហរក្រោកមកប្រឈមនឹងនាយវិញជាមួយទឹកមុខមិនសប្បាយចិត្ត។ នាងនិយាយខ្លីៗ៖

«ខ្ញុំអត់អីទាំងអស់! ឆាប់ទៅមុនទៅ ពូសំភិនមានគ្រោះថ្នាក់! ហើយពេទ្យឯងដើរខុសផ្លូវហើយ!»

«ផ្លូវកាត់!»

គេឆ្លើយខ្លីហើយបន្តសម្លឹងដៃនាងដែលផ្ទប់បិទបាំងកអាវ។ មុនដក់ភ្នែកចេញគេនិយាយបន្ថែម៖

«ដើរបានមែនអត់នៀក?!»

នាងវេភ្នែកសម្លឹងឈាមរហាចនៅក្បែរភ្នែកគោល។

សំណាងហើយវារបួសដាច់ដោច តែមិនបានភ្លាត់ដល់សរសៃ កុំអីត្រូវមានអ្នកអៀវទៅដូចក្នុងកុន?

ប៉ុពេទ្យគួរឱ្យជិននេះហ្មែន ដែលជាហេរ៉ូមកអៀវយើងទៅ?

នាងដើរត្រដាបត្រដួសរឹងទៅមុនបុរសនេះ ជាចម្លើយមិនបាច់ហើបមាត់ថា នាងដើរបាន មិនខ្វីឱ្យអ្នកណាមកអាណិតយកអសាររទេ។

## ជំពូកទី៤

## បន្ទប់ផ្ការំចេក

«គាត់ខ្សោយខ្លាំង! តែពេលនេះចាក់ថ្នាំ និងព្យួរសេរ៉ូមហើយអស់អីហើយ! ឱ្យគាត់ហូបចុកទៀងពេល និងពិសាថ្នាំជាប់លាប់!»

ធីតាចូលចិត្តការងាររបស់ពេទ្យសានដ៏មានចរិតចម្លែកម្នាក់នេះ។ ទោះបីគេមានវិធីទំនាក់ទំនងដ៏អន់ថយនិងមានទឹកមុខយ៉ាប់ៗ ប៉ុន្តែវិជ្ជាពេទ្យរបស់គេហាក់ស្ទាត់ជំនាញ។ គេមានការទាក់ទងជិតដិតណាស់ជាមួយអ្នកផ្ទះនេះ អ៊ីចឹងហើយបានជាភ្លាមៗបងចរិយារបស់នាងបានឱ្យនាងរត់ទៅហៅគេ។

ស្រីតូចចាកចេញពីអ្នកជំងឺនិងពេទ្យចម្លែកនោះ មកស្គាល់បន្ទប់សម្រាកដែលនាងនឹងត្រូវទទួលពិសោធន៍ជាលើកដំបូងក្នុងការរស់នៅក្នុងវិមានក្រអូប។

«គេងនៅនេះណ៎ាធីតា! ថ្ងៃនេះរញ៉េរញ៉ៃបន្តិច ព្រោះមីងមៀចក៏មិននៅ កូនគាត់បងម៉ៅរវល់ទៅផ្សារ! តែមិនអីទេ! ត្រូវការអី អាចហៅបងគ្រប់ពេល បន្ទប់បងនៅទីពីរនោះ!»

ជំទាវចង្អុលទៅបន្ទប់មួយជួរនៅពីមុខផ្លូវចូល។ បន្ទប់ឈើច្រើនហើយមានរចនាបទដូចសណ្ឋាគារផ្កាយ៥ បង្ហាញពីរបៀបរស់នៅដ៏ប្រណីតស្តុកស្តម្ភនៃគ្រួសារនេះ ចំណែកឯពីរនាក់អំបាញ់មិញ «មីងមៀចក៏មិននៅ បងម៉ៅរវល់ទៅផ្សារ» ធីតាស្មានដឹងថាជាឈ្មោះក្រុមអ្នកជំនួសដៃជើងក្នុងគ្រួសារ។

«ពេទ្យមិញទៅបាត់ហើយហ្អីបង?!»

នាងសួរកាត់។

ចរិយាងក់ក្បាលជំនួសចម្លើយ។ ធីតាសួរបន្ថែម៖

«គេហ្នឹងជាពេទ្យប្រចាំគ្រួសារយើង?!»

«ចាស៎!» ជំទាវឆ្លើយមកដោយមិនបានបង្អង់ទេ។

«អញ្ចឹងបានអញ្ចឹង!» ធីតារអ៊ូតិចៗ ធ្វើឱ្យចរិយាបង្អង់ដំណើរងាកមកសួរតិចៗហាក់ឆ្ងល់៖

«មានរឿងអីហ្អែន?!»

ធីតាដឹងថាខ្លួនមានប្រតិកម្មរហូតពញ្ញាក់កូនប្រសាម្ចាស់ផ្ទះ នាងក៏សម្រួលសម្ដីមកវិញ៖

«មានហ្នា! គ្រាន់តែគេហ្នឹងស្គាល់ផ្លូវកាត់ច្រើន! ដំបងខ្ញុំរាងឆ្ងល់ដែរតែតឡូវអស់អីហើយ!»

ចរិយាសើចទាំងកែវភ្នែកស្រងូត៖

«កុំប្រកាន់ទឹកមុខនិងសម្ដីសំដៅគេ! ពេទ្យសាននេះពូកែហើយចិត្តបានណាស់! សម្រាប់គ្រួសារនេះគាត់ជួយមិនរើសពេលវេលាទេ ហៅថ្មើរណាបានថ្មើរហ្នឹង!»

នាងនឹកឃើញដល់ហាងថ្នាំស្វាត់ជ្រងំរបស់គេនោះភ្លាមឡើងវិញមួយរំពេចទាំងភ្លាត់មាត់និយាយទៅតាមអារម្មណ៍របស់ខ្លួន៖

«ហ្វាម៉ាស៊ីគេហ្នឹងគួរតែមានទូរសព្ទមួយគ្រាន់ទាក់ទងគ្នា!»

ចរិយាសើចបន្ថែមស្ងួតស្ងប់។ នាងដឹងថាប្អូនជីដូនមួយសាច់ថ្លៃម្នាក់នេះ កំពុងបន្ទោសដែលខ្លួនបណ្ដោញនាង ឱ្យរត់ទៅតាមរកពេទ្យសានថ្នាក់ហត់គយូសនិងរបួសជើងទៀត។

«កន្លែងយើងអត់សេវាទេ!»

ធីតាបើកភ្នែកធំជាងមុន ហើយអោនឆែកទូរសព្ទខ្លួន។

«របៀបរស់នៅបែបនេះហើយដឹងដែលពូរុទ្ធីប្រាថ្នាចង់បាន!»

នាងគិតម្នាក់ឯងដោយហួសចិត្ត។

«សម្រាកទៅ! បងទៅផ្ដាំពូសំភិនរឿងថ្នាំរបស់គាត់សិន! តិចទៀតបងម៉ៅមកវិញ មានម្ហូបបាយមកពីហាងដែលបងកុម្ម៉ង់ ចាំបងឱ្យគេរៀបចំ!»

នារីមកស្នាក់ ងក់ក្បាលតិចៗមិនឆ្លើយតប។ ដៃនាងបោះទូរស័ព្ទទៅលើកម្រាលពូកពណ៌សក្បុសដូចក្នុងResort ដែលត្រូវបង់ថ្លៃសេវាកម្មរាប់រយដុល្លារអាមេរិក។ តាមពិនិត្យផ្ទះនេះ បន្ទប់ច្រើនយ៉ាងនេះហើយស្អាតកម្រិតនេះ មិនសមណាអាចរ៉ាប់រងបម្រើថែទាំ ត្រឹមតែមីងមៀចនិងមនុស្សឈ្មោះម៉ៅតែពីរនាក់អ៊ីចឹងសោះគួរតែ១០នាក់ឡើង។

ហាក់នឹកឃើញដល់រឿងអ្វីមួយ នាងងាកមករកលោកជំទាវតូចដែលកំពុងរៀបចំចាកចេញពីទីនេះ។

«បងចរិយា! មានដំណឹងពីបងប្រុសខ្ញុំទេ?»

នាងសម្ដៅដល់សហគ្រិនល្បីលោក វុទ្ធី ឧត្តម ជាកូនប្រុសតែមួយគត់នៃម្ចាស់ផ្ទះនេះ ក៏ជាស្វាមីនៃស្រីរូបស្អាតមានឈ្មោះថា ជំទាវចរិយា នេះ។

គេបានបាត់ខ្លួនគ្មានដំណឹងប្រមាណជា ៤ខែមកហើយ។ មុនពេលឪពុកបង្កើតត្រូវធ្លាក់ស្លាប់ ប៉ូលិសមិនដែលរកឃើញតម្រុយអំពីដំណឹងរបស់គេទាល់តែសោះ។

ជំទាវចរិយាឈប់ដំណើរហើយបែរមកវិញដោយក្រៀមក្រំ។

នាងគ្រវីក្បាលយឺតៗជំនួសចម្លើយ។

«ផ្ទះនេះពិតជាមានរឿងច្រើនមែន»

ធីតាគិតក្នុងចិត្តដោយស្រពោន។

«គេងដាក់រនុកទ្វារផង!»

ផ្ដាំចប់កូនប្រសាស្រីគេហដ្ឋាននេះបែរខ្លួនចាកចេញទៅ។

ធីតាសម្លឹងទ្វារ បន្ទាប់មកនាងពិនិត្យបង្អួចហួសទៅសួនខាងក្រៅ ចុងក្រោយក្រឡេកមកគ្រែនិងពូកល្វែ។ នាងបម្រុងប្រះមកលើកម្រាលពូកតាមបញ្ញានៃភាពនឿយហត់ តែនាងដូរចិត្តមកអង្គុយលើកៅអីឈើ វែងខ្មៅរលោងវិញ ព្រោះដឹងថារបួសជើងនិងធូលីលើដងខ្លួនអាចបំផ្លាញសម្រស់នៃគ្រែដេកដ៏វិចិត្រនេះបាន។

ខួរក្បាលនារីអ្នកសារព័ត៌មាន ដែលជានិច្ចជាកាលរក្សាការគិតពិចារណាជាអចិន្ត្រៃយ៍ លើវិបត្តិគ្រួសារចាក់ស្រេះមួយនេះ ស្រាប់តែចាប់អារម្មណ៍ថាធូរស្រាលជាមួយនឹងពិដោរក្រអូបផ្អែម នៃជាតិបុស្បាម្យ៉ាងដែលអាចចាប់ទាញបបូរមាត់នារីឱ្យញញឹមស្រស់បាន។

«រំចេក! ផ្ការំចេកពិតណាស់! ខានស្គាល់ក្លិនយូរហើយ!»

កម្លាំងនៃរសបុប្ផា អាចនាំមកនូវអំណាចជាវិជ្ជមានបង្កើតកម្លាំងព្រឹសដល់ធីតា ក្រោកឡើងមកចរយាត្រាពិនិត្យពិច័យស្ថានភាពខាងក្រៅបង្អួច។

នាងទាញរបើកវាំងននសន្លឹកកម្ញីក្រាស់ពណ៌សដូចគជ់រលោង។ ខាងក្រៅមេឃងងឹតប្រិមៗ ដ្បិតតែមិនទាន់ដល់ថ្នាក់ស្លុបតែម្ដងតែព្រះអាទិត្យលែងឃើញទាំងស្រុង សល់តែស្រមោលក្រហមព្រឿងៗនាដែនឆ្ងាយសន្លឹម។ តាមរយៈផ្ទៃកញ្ចក់បិទបាំង តើផ្កាវំចេកបង្ហើរក្លិនមកបរិវេណខាងក្នុងតាមណាកើតទៅ?

នាងបែរក្រោយពិនិត្យទូទាំងបន្ទប់។

លើកូនតុឈើចម្លាក់ផ្នែកខាងស្ដាំក្បាលដំណេក តួផ្កាមួយលម្អដោយបាច់ផ្កាស្រស់ប៉ប្រិម។ វាគួរតែទើបកាច់មកក្នុងថ្ងៃនេះ? ហើយអ្នកណាជាអ្នកធ្វើ? ម៉េចគេដឹងថាបន្ទប់នេះមានភ្ញៀវមកស្នាក់?

**ជំពូកទី៥**

## ឯកសារក្នុងដៃប៉ូលិស

«យប់មិញខ្ញុំគេងនៅនោះពេញមួយយប់! ប៉ុន្តែនៅមិនទាន់បានឃើញ ឬបានពិនិត្យជណ្ដើរនោះនៅឡើយ! គឺចង់និយាយពីកន្លែងដែលបាក់នោះធ្លាក់មាខ្ញុំ! និយាយទៅ បន្ទប់កើតហេតុនោះ គេចាក់សោលែងឱ្យចេញចូលហើយ! កូនសោក៏នៅនឹងជំទាវមីងទៀត គាត់មិនទាន់មកដល់ផង!»

អ្នកកំពុងអង្គុយស្ដាប់នាងពុំមែនជាពេទ្យសានទេ ប៉ុន្តែអធិការភារម្យដែលនាងសៅហ្មងដាក់កាលពីម្សិល។ វត្តមាននារីអ្នកកាសែតវិលមកអធិការដ្ឋានវិញ ពុំមែនជាការរំពឹងទុករបស់គ្រប់គ្នាទេ ប៉ុន្តែភារម្យនៅតែរក្សាការស្ងប់ស្ងាត់ មិនចំអក ឬផ្ចាញ់ផ្ចាលអ្វី ថែមទាំងសម្ងំស្ដាប់នាងដោយយកចិត្តទុកដាក់។

សភាពនារីនេះ នាងខូងភ្នែកទាំងសង ទំនងគេងមិនបានពេញលេញស្កប់ស្កល់ទេកាលពីយប់មិញ។ ម្សិលមិញចាកចេញទៅ ដោយខឹងសម្បាផង មិនសមថាព្រឹកព្រហាមកាលណាក៏ឡើងមករកនាយប៉ូលិសមុនគេ ថែមទាំងនិយាយរៀបរាប់ច្រើនយ៉ាងនេះ?

«ខ្ញុំមានរឿងមួយចំនួននៅមិនទាន់បានសួរ! ប្រសិនអាចខ្ញុំចង់សុំឯកសារទាំងអស់ដែលប៉ូលិសរកឃើញ ក្នុងសំណុំរឿងមរណភាពលោកពូខ្ញុំ!»

នាងនិយាយយ៉ាងញាប់ក្រោមការរង់ចាំស្ដាប់ដោយអត់ធ្មត់របស់ប៉ូលិសភារម្យ។ នាងជាអ្នកសារព័ត៌មានហើយមានប្រវត្តិសិក្សាអប់រំខ្ពស់ទៀត ប្រសិននាងតាំងចិត្តថានឹងមកស៊ើបក្ដីជំនួសប៉ូលិស នាងក៏គួរដឹងជាស្រេចហើយថាប៉ូលិសមិនសហការការងារសម្ងាត់ក្រៅរង្វង់ច្បាប់ទេ។

អធិការភារម្យគិតហើយ តែគេនៅស្ងៀមមិនតប គ្រាន់តែដៀងភ្នែកសម្លឹងពែងកាហ្វេក្រដាសប្រេនៗ ដែលនាងនាំមកជាមួយ។ នារីនេះមានកិរិយាជាយុវវ័យទីក្រុងធំច្បាស់ៗ ហើយអមដោយចិត្តថ្លើមរឹងមានះ។ តើនាងរឹងមាំស្មើនឹងភាពមានះរបស់នាងដែរទេ?

គេសម្លឹងនាងដើម្បីពិនិត្យពិច័យអាការៈផុយស្រួយងាយខឹងសម្បារបស់នាង។

«និយាយម្ដងទៀតក៏បានខ្ញុំសុំឯកសារលម្អិតជុំវិញការស្លាប់របស់លោកពូខ្ញុំ!»

«ឱ្យមិនបានទេ!» នាយអធិការឆ្លើយយ៉ាងរហ័សទាំងផ្ដោតសម្លឹងភ្នែកមូលក្លំរបស់នាង។

ប៉ូលិសភារម្យត្រៀមលក្ខណៈស្រេចហើយក្នុងការរងប្រតិកម្មមិនសប្បាយចិត្តនៃនារីនេះដែលនាងមិនសមបំណង  ប៉ុន្តែផ្ទុយពីការគិតរបស់គេ នាងបានត្រឹមបើកភ្នែកធំៗតែក៏មិនជាមានប្រតិកម្មអ្វីក្រៅពីផ្អែកខ្នងទៅលើកៅអីហាក់អស់កម្លាំងចិត្ត។

«ប៉ូលីសបានធ្វើការតាមតួនាទី តាមគោលការណ៍ច្បាប់អស់ហើយ! សំណុំរឿងត្រូវបានបិទ! គ្រប់គ្នាទទួលស្គាល់ថា ការស្លាប់ជាឧប្បត្តិហេតុ! ចំណែកឯកសារក៏មិនអាចប៉ះពាល់បាន! ខ្ញុំត្រូវសុំទោស! សំណៅរបាយការណ៍សន្និដ្ឋានសរុបចុងក្រោយ ខ្ញុំអាចឱ្យបាន»

«ខ្ញុំមានហើយ! ក្នុងនោះគ្មានអីទាំងអស់ គ្រាន់តែនិយាយលំៗថាជាការស្លាប់គ្រោះថ្នាក់ចៃដន្យ!»

នាងឆ្លើយទោមនស្សដោយណាស់ ព្រោះមានអារម្មណ៍ថា បុរសនេះកំពុងឌឺដង។ ចំពោះមុខធីតាពិតជាត្រូវការពន្លឺច្រើនដើម្បីស្វែងរកឱ្យដល់ការពិត  ហើយនាងដឹងថាបុរសនេះមានតម្រុយសំខាន់ៗក្នុងដៃ។

ការអង្វរករលួងលោមគេមិនមែនជាចរិតរបស់ធីតាស្រាប់ហើយ ដូច្នេះនាងបានត្រឹមនៅសម្ងំស្ងៀមរិះរកវិធីសាស្ត្រ។

ដៃរាវទន់ល្វតឈោងចាប់ពែងកាហ្វេមកក្រេបតិចៗ។ បានបន្តិចនាងនិយាយរអ៊ូបន្ទោសៈ

«ប៉ូលិសបានស៊ើបមិនដល់១០ថ្ងៃផងក៏សុខចិត្តបញ្ចប់វាត្រឹមហេតុផលថាគ្រោះថ្នាក់ចៃដន្យ! អស្ចារ្យណាស់!»

ប៉ូលិសភារម្យមិនបានថមថយកិរិយារឹងមាំរបស់ខ្លួនទៅណាទេ។ គេនិយាយតបមួយៗដោយមិនដកភ្នែកចេញពីគូសន្ទនាៈ

«ព្រោះគ្មានអ្វីរីកចម្រើន!»

«លោកអាចពន្យល់ខ្ញុំ! ម្ដេចទៅដែលហៅថាមិនរីកចម្រើន!»

បុរសនេះតាមថាអាចបដិសេធនឹងភាពទទឹងទិសរបស់នាង តែគេបែរជាមានចិត្តមួយយល់ថានារីនេះមានភាពអស្មិមានៈដិតដាមជាមួយការគិតបែបផ្សេងរបស់នាង។ ប្រសិនបើមិននិយាយឱ្យច្បាស់លាស់នាងទំនងជានៅចិញ្ចឹមចិត្តខាតពេលវេលាជាមួយការស្រមៃមួយនេះមិនងាយចប់ទេ។

«កាហ្វេអស់នៅ? ខ្ញុំចង់ប៉ាវកាហ្វេរតនគីរីមួយកែវទៀត!»

នាងងើបមុខសម្លឹងបុរសនេះ ឃើញគេញញឹម។ ស្នាមញញឹមគេនេះ មើលទៅទំនងដូចទន់ភ្លន់ម្យ៉ាងដែរ បើធៀបនឹងជំហរមិនសហការដ៏រឹងរូសគ្មានយោគយល់របស់គេកន្លងមក។

ស្រីស្អាតរេភ្នែកសម្លឹងពែងកាហ្វេប្រេន ហើយភ្លាត់សើច។ នាងនិយាយ៖

«មែនតាស់! គួរតែប្ដូររសជាតិដែរ!»

នាងក្រោក គេក៏ក្រោកមកជាមួយ។ ប៉ូលិសវ៉ាចាបន្ថែមទាំងអោនបិទកុំព្យូទ័រ និងស្រវាប្រមូលទូរសព្ទអាយកូមមកតាមខ្លួន៖

«ហើយធីតាអាចនឹងមកញ៉ាំវារាល់ថ្ងៃជំនួសកាហ្វេបរទេស!»

នាងព្រិចភ្នែកតិចៗសម្លឹងបុរសនេះ កាយវិការរហ័សរហួនរបស់នាយ ភាពជឿជាក់ ហាក់ដូចជាថ្មីសម្រាប់នាងដែលចង់ពិនិត្យពិច័យបុរសនេះជាងកាលពីជួបម្សិលមិញ។ ធីតាបែរខ្លួនទៅតាមពីក្រោយដំណើរគេដែលកំពុងនាំផ្លូវ។

មួយក្រឡេកភ្នែកចុងក្រោយ នាងចាប់អារម្មណ៍ឃើញរូបថតក្មេងប្រុសម្នាក់ តាំងលើជ្រុងខាងស្ដាំនៃតុធ្វើការនាយអធិការ ធ្វើឱ្យភាពដណ្ដឹងសួរលេចឡើងក្នុងចិត្តស្ងាត់ៗ៖

«ចង់ឃើញមុខប្រពន្ធម្នាក់នេះដែរតើ តើរូបរាងម៉េចវិញ?!»